IUCN
The World Conservation Union

## សេចក្ដីប្រកាសព័ត៌មាន

**<u>សំរាប់ចេញផ្សាយបន្ទាន់</u>**

**អង្គការសហភាពអភិរក្សពិភពលោក ប្រចាំប្រទេសកម្ពុជា**
**ភ្នំពេញ ថ្ងៃសុក្រ ទី ២៥ ខែ ឧសភាឆ្នាំ ២០០៧**

# វិធីសាស្ត្រគ្រប់គ្រងប្រព័ន្ធអេកូឡូស៊ី ដោយមានការរួមបញ្ចូលជីវភាពសហគមន៍ក្រីក្រ

ជារឿយៗគេតែងតែលឺថា ការគ្រប់គ្រងតំបន់ការពារធម្មជាតិដោយរួមបញ្ចូលនូវការអភិវឌ្ឍន៍ជីវភាពរស់នៅរបស់សហគមន៍មូលដ្ឋានគឺពិបាកនឹងធ្វើទៅបានណាស់ តែវាប្រហែលជានឹងអាចធ្វើទៅបាន ហើយនឹងក្លាយជាប្រវត្តិសាស្ត្រក្នុងពេលឆាប់ៗខាងមុខតាមរយៈការបង្កើតយុទ្ធសាស្ត្រថ្មីមួយរបស់អង្គការសហភាពអភិរក្សពិភពលោក (IUCN)[១] ដោយមានការសហការជាមួយនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិនៃក្រសួងបរិស្ថានដោយមានការឧបត្ថម្ភពីគំរោងនៃគំនិតផ្ដួចផ្ដើមដាវីននៃចក្រភពអង់គ្លេស (UK Darwin Initiative)[២]។

ចាប់ពីល្បាក់ខោននៃប្រទេសឡាវ និងហូរចូលមកប្រទេសកម្ពុជា ទន្លេមេគង្គផ្លាស់ប្ដូរទ្រង់ទ្រាយរបស់វាប្រកបដោយវិសាលភាពទៅជាតំបន់ដែលមានលក្ខណៈពិសេសតែមួយដែលមានព្រៃលិចទឹក ព្រៃគុម្ពោត កោះជាច្រើនដែលសំបូរទៅដោយផ្ទុកខ្សាច់ និងគ្រួស ទឹកហូរខ្លាំង ទឹកគួច និងអន្លង់ជ្រៅៗ។ ទីនេះត្រូវបានកំណត់ជាតំបន់រ៉ាមសារ (Ramsar)[៣] សំរាប់អភិរក្សតំបន់ដីសើមដែលមានសារៈសំខាន់អន្តរជាតិកាលពីថ្ងៃទី ២៣ តុលា ១៩៩៩។ តំបន់នេះមានប្រភេទសត្វដែលកំរ និងកំពុងរងការគំរាមកំហែងដែលមានចុះនៅក្នុងបញ្ជីក្រហមរបស់អង្គការសហភាពអភិរក្សពិភពលោក (IUCN Red List)[៤] ដូចជា សត្វត្រយ៉ងចំកំស រំពេទន្លេ ក្រពើត្រី ផ្សោតទន្លេ និងប្រភេទសត្វជាច្រើនទៀត។

នៅក្នុងឆ្នាំ ២០០៦ ការសិក្សាវាយតំលៃនៃបរិស្ថានតំបន់រ៉ាមសារស្ទឹងត្រែងបាននាំទៅរកសំណើរនៃការបង្កើតជាតំបន់គ្រប់គ្រងមួយចំនួនដែលការនេសាទ និងសកម្មភាពនានាមិនត្រូវបានអនុញ្ញាតទេក្នុងសំណើតំបន់គ្រប់គ្រងនៃតំបន់

---

[១] គំរោងនេះគឺដឹកនាំដោយ IUCN Species Programme's **Freshwater Biodiversity Unit** ជាមួយនិង គំរោងជាដៃគូមកពី **Overseas Development Group** (University of East Anglia, UK), **IUCN** ប្រទេសស៊ីរីលង្កា កម្ពុជា វៀតណាម តង់ហ្សានា និង ការិយាល័យ **IUCN Eastern Africa Regional** មើលគេហទំព័រ: http://www.iucn.org/themes/ssc/our_work/freshwater/darwin_index.htm

[២] រដ្ឋាភិបាលចក្រភពអង់គ្លេសលើកតំកើងការអភិរក្សជីវចម្រុះ និងការប្រើប្រាស់ដោយនិរន្តរភាពនូវធនធានធម្មជាតិតាមរយៈគំនិតផ្ដួចផ្ដើមដាវីន (**Darwin Initiative**) មើលគេហទំព័រ: http://www.iucn.darwin.gov.uk/

[៣] អនុសញ្ញានៃតំបន់ដីសើមដែលមានសារៈសំខាន់ជាអន្តរជាតិ ជាពិសេសជំរកសត្វស្លាបទឹក។ រ៉ាមសារ (ប្រទេសអ៊ីរ៉ង់) ថ្ងៃទី ២ ខែកុម្ភៈ ១៩៧១ មើលគេហទំព័រ: http://www.ramsar.org/

[៤] មើលគេហទំព័រ: http://www.iucnredlist.org/

ODG DEV　DARWIN INITIATIVE　SSC Species Survival Commission

រ៉ាមសារស្ទឹងត្រែងនេះ។ អនុសាសន៍ពីការវាយតំលៃនេះដែលផ្អែកតែទៅលើតែទស្សនវិស័យនៃការអភិរក្សជីវៈចម្រុះតែមួយមុខនោះបានសន្និដ្ឋានថា មានការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងសំណើតំបន់គ្រប់គ្រងមួយចំនួនដែលបានស្នើសុំនោះតិចតួចប៉ុណ្ណោះពីសំណាក់សហគមន៍មូលដ្ឋាន ដែលការសន្និដ្ឋាននេះគឺជាការដែលយល់ខុសពីអ្វីដែលបានរកឃើញដោយក្រុមសិក្សាស្រាវជ្រាវរួមនៃអង្គការសហភាពអភិរក្សពិភពលោក និងគំរោងនៃគំនិតផ្តួចផ្តើមដាវីននាពេលថ្មីៗនេះដែលបានបង្ហាញអោយឃើញពីការពឹងពាក់ជាសំខាន់របស់សហគមន៍មូលដ្ឋានលើការប្រើប្រាស់ធនធានធម្មជាតិនានានៅក្នុងតំបន់ទាំងឡាយដែលបានស្នើសុំនោះ។

នៅ ខែមករា និង កុម្ភៈ ឆ្នាំ ២០០៧ តាមរយៈគំរោង **ពង្រឹងការអភិរក្សតំបន់ដីសើមមុនពេលធ្លាក់ដុនដាបដោយប្រើប្រាស់ការវាយតំលៃរួមរវាងជីវៈចម្រុះ និងជីវភាពរស់នៅ** របស់អង្គការសហភាពអភិរក្សពិភពលោក និងគំនិតផ្តួចផ្តើមដាវីន ដែលការសិក្សាវាយតំលៃនេះត្រូវបានធ្វើឡើងដោយផ្តោតជាសំខាន់ទៅលើផលប៉ះពាល់លើជីវភាពរស់នៅ ជីវៈចម្រុះ និងសេដ្ឋកិច្ចដែលបណ្តាលមកពីសំណើនៃការបង្កើតតំបន់គ្រប់គ្រងនេះ។ លទ្ធផលបានបង្ហាញអោយឃើញថា ផែនការប្រតិបត្តិដោយតឹងរ៉ឹងទៅលើតំបន់ដែលបានស្នើសុំនោះវានឹងជះឥទ្ធិពលដល់ប្រជាជនដែលក្រីក្របំផុត ក្នុងចំណោមអ្នកក្រីក្រទាំងនេះរួមបញ្ចូលទាំងអ្នកតាំងទីលំនៅទេសន្តរប្រវេសន៍ និងអ្នកដែលខ្វះខាតដីធ្លីដែលអ្នកទាំងនោះពឹងផ្អែកជាចំបងលើប្រាក់ចំណូលដែលបានមកពីការនេសាទ និងអាជីវកម្មត្រីសំរាប់ផ្គត់ផ្គង់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពួកគាត់។ ព្រះសាខនគឺជាសំណើតំបន់គ្រប់គ្រងមួយក្នុងចំណោមសំណើរតំបន់គ្រប់គ្រងដែលបានស្នើសុំនៅក្នុងតំបន់រ៉ាមសារស្ទឹងត្រែង។ លោក **ម៉ាក ឌូប័រ** អ្នកជំនាញការខាងជីវភាពរស់នៅនៃក្រុមការងាររបស់អង្គការសហភាពអភិរក្សពិភពលោក និងគំរោងនៃគំនិតផ្តួចផ្តើមដាវីនបានមានប្រសាសន៍ថា អ្នកដែលប្រើប្រាស់តំបន់ព្រះសាខននេះជាចំបងនោះគឺអ្នកនេសាទដែលក្រីក្រ ជាពិសេសនោះការនេសាទត្រីរវៀលក្នុងអំឡុងពេលនៃការផ្លាស់ទីដើម្បីរកទីកន្លែងពងកូនរបស់ប្រភេទត្រីនេះ។ លោក **គង់ គីម ស្រេង** មន្ត្រីនៃអង្គការសហភាពអភិរក្សពិភពលោក និងជាទីប្រឹក្សាផ្នែកជីវៈចម្រុះនៃក្រុមការងាររបស់អង្គការនេះជាមួយនិងគំរោងនៃគំនិតផ្តួចផ្តើមដាវីនបានបន្ថែមថា តំបន់ផ្នុកខ្សាច់នៃតំបន់ព្រះសារខនគឺជាជំរកដ៏សំខាន់មួយសំរាប់ការធ្វើសំបុកពងកូនរបស់ប្រភេទសត្វដែលកំរ និងកំពុងរងការគំរាមកំហែងដូចជាសត្វរំពេទន្លេ ទន្ទីមនឹងទីជំរកនៃព្រៃខ្ពស់ៗដទៃទៀតតាមទន្លេ និងប្រឡាយនានានៅក្នុងតំបន់នេះជាទ្រនុំ និងសំបុកពងកូនរបស់ប្រភេទសត្វផ្សេងៗដូចជាហ្វូងក្អែកទឹក និងស្មោញជាដើម។

ការគ្រប់គ្រងតឹងរ៉ឹងក៏អាចជាកត្តាដែលនាំអោយប្រជាជនមូលដ្ឋានបង្កើនការប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ព្រះសាខនកាន់តែច្រើនឡើងថែមទៀត។ អ្នកភូមិកោះល្វៃដែលរស់នៅជាប់នឹងព្រំប្រទល់ខាងលើនៃតំបន់រ៉ាមសារស្ទឹងត្រែងបានមានប្រសាសន៍ថា "ខ្ញុំមកបោះជំរុំដើម្បីធ្វើការនេសាទនៅទីនេះ ពីព្រោះតែមានការគ្រប់គ្រងតឹងរ៉ឹងលើការនេសាទដោយបទបញ្ជានៃការអភិរក្សសត្វផ្សោតនៅជុំវិញតំបន់អន្លង់ឈើទាល និងតំបន់នេសាទដទៃទៀតរបស់អ្នកភូមិដែលនៅក្បែរនោះ ខ្ញុំត្រូវធ្វើដំណើរឆ្ងាយពីភូមិដើម្បីធ្វើការនេសាទ"។ ដំណោះស្រាយក្នុងជំរើសនៃការគ្រប់គ្រងអាចសំរេចបានដោយការទទួលយកទស្សនវិស័យបីមកធ្វើការពិនិត្យ និងពិចារណាដើម្បីដាក់បញ្ចូលទៅក្នុងជំរើសនៃការគ្រប់គ្រងនោះ ទស្សនវិស័យទាំងបីនោះគឺ សារៈសំខាន់នៃកត្តារដូវកាលនៃការធ្វើអាជីវកម្មទៅលើធនធាន "ត្រី" ទីជម្រកនៃជីវៈចម្រុះ និងទីជំរកពងកូនរបស់សត្វនានានៅក្នុងតំបន់។ នាសិក្ខាសាលាខែកុម្ភៈ ឆ្នាំ ២០០៧ នៅខេត្តស្ទឹងត្រែងដែលបង្ហាញអំពីលទ្ធផលនៃការសិក្សាវាយតំលៃនៃតំបន់រ៉ាមសារស្ទឹងត្រែងដោយមានការចូលរួមពីមន្ត្រីដែលពាក់ពន្ធ័ថ្នាក់ស្រុក ថ្នាក់ជាតិ និងប្រជាជនមូលដ្ឋាននោះ ការសន្និដ្ឋានបានសម្រេចថា តំបន់ព្រះសាខនគួរដាក់ជា

IUCN
The World Conservation Union

តំបន់ដែលពុំគ្រប់គ្រងតឹងរឹងខ្លាំងពេក នោះគឺដោយអនុញ្ញាតអោយប្រជាជនអាចចូលបានក្នុងអំឡុងពេលនៃរដូវកាលនេសាទត្រីរៀល ដែលសកម្មភាពនេសាទនៅរដូវកាលនោះមានការប៉ះពាល់តិចតួចប៉ុណ្ណោះដល់ជីវៈចម្រុះដទៃទៀត។ បទបញ្ជា និងគោលការណ៍ណែនាំដទៃទៀតក៏ត្រូវបានលើកឡើង និងទទួលយកផងដែរក្នុងអំឡុងពេលនៃសិក្ខាសាលានោះ។ ប៉ុន្តែបញ្ហាដែលធំជាងគេដែលត្រូវប្រឈមមុខនាពេលបច្ចុប្បន្នគឺការសម្រេចចិត្តថា បទបញ្ជានានាដែលមានស្រាប់សំរាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិអាចផ្លាស់ប្តូរ ឬ បត់បែនបានក្នុងការទទួលយកដំណោះស្រាយខាងលើសំរាប់ការការពារ ទាំងជីវៈចម្រុះ និង ជីវភាពរស់នៅរបស់សហគមន៏មូលដ្ឋានដែរឬទេ។

---

**កំណត់សំគាល់**

សំរាប់ពត៌មានបន្ថែម ឬកាសំភាសន៏អំពីការសិក្សាស្រាវជ្រាវរួមរបស់អង្គការសហភាពអភិរក្សពិភពលោក និងគំរោងនៃគំនិតផ្តួចផ្តើមដាវីននៅតំបន់រ៉ាមសារស្ទឹងត្រែងនេះសូមទាក់ទង


លោក **គង់ គីម ស្រេង**
មន្ត្រីអង្គការសហភាពអភិរក្សពិភពលោកនៃប្រទេសកម្ពុជា
ផ្ទះលេខ ១៩ ផ្លូវ ៣១២ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ
ប្រអប់សំបុត្រ ១៥០៤ ភ្នំពេញ
ទូរស័ព្ទលេខ: ៨៥៥ (០២៣) ២២២ ៣១១ លេខភ្ជាប់ ១១៤
ទូរសារ: ៨៥៥ (០២៣) ២២២ ៣១២
ទូរស័ព្ទចល័ត: ៨៥៥ (០)១២ ៨៨៨ ៨៤៧
អ៊ីមែល: kksreng@iucncambodia.org


**រូបថតពីការសិក្សាស្រាវជ្រាវនៅតំបន់រ៉ាមសារស្ទឹងត្រែងនេះ** អាចរកបាននៅការិយាល័យអង្គការសហភាពអភិរក្សពិភពលោកនៃប្រទេសកម្ពុជា

**អំពីអង្គការសហភាពអភិរក្សពិភពលោក**

បង្កើតឡើងនៅឆ្នាំ ១៩៤៨ អង្គការនេះមានសមាជិកចំនួន ៨១ រដ្ឋ ១២០នៃភ្នាក់ងាររដ្ឋាភិបាល លើសពី៨០០ នៃអង្គការក្រៅរដ្ឋាភិបាល និង ១០០០០នាក់នៃអ្នកវិទ្យាសាស្ត្រ និងជំនាញការមកពី ១៨១ ប្រទេសដែលជាដៃគូ នៅជុំវិញពិភពលោក។ បេសកម្មរបស់សហភាពនេះគឺ លើកទឹកចិត្ត និងជួយជំរុញសង្គមក្នុងពិភពលោកដើម្បីអភិរក្សនូវបូរណៈភាពនៃនានាភាពរបស់ធម្មជាតិ និងដើម្បីប្រាកដថាការប្រើប្រាស់ធនធានធម្មជាតិនានាគឺប្រកបដោយសមធិ និងធានាបាននូវនិរន្តរភាពតាមបរិស្ថានវិទ្យា។ សហភាពនេះគឺជាបណ្តាញចំណេះដឹងនៃបរិស្ថានដែលធំជាងគេបំផុតលើពិភពលោក និងបានជួយលើប្រទេសចំនួន ៧៥ ក្នុងការរៀបចំ និងអនុវត្ត ការអភិរក្ស និង យុទ្ធសាស្ត្រជីវៈចម្រុះជាតិ។ សហភាពនេះគឺជា អង្គការពហុវប្បធមិ ភាសាចំរុះ ជាមួយនិងបុគ្គលិកចំនួន ១០០០នាក់ ដែលស្ថិតនៅ ក្នុងប្រទេសចំនួន ៦២ ផ្សេងគ្នា។

ODG DEV · DARWIN INITIATIVE · SSC Species Survival Commission